## អង្គរបុរី
### សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ត្រូវជំរុញតុលាការកាត់ទោសខ្មែរក្រហមឲ្យបានឆាប់ មិនត្រូវបង្អាក់ដំណើរឡើយ ។

website: www.hoksavann.org

ថ្ងៃទី១៩ កញ្ញា ២០០៧



ព្រះពុទ្ធសាសនាបានពោលថា ផលអ្វីមួយកើតឡើងសុទ្ធតែមានហេតុរបស់វា ។ ឫសគល់ដែលនាំឲ្យខ្មែរក្រហមកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរអស់រាប់លាននាក់នេះ គឺអកុសលចិត្ត លោភៈ ទោសៈ មោហៈ អវិជ្ជា និង មិច្ឆាទិដ្ឋិរបស់ពួកនេះ ។ ព្រឹត្តិការណ៍កើតឡើង គឺពួកកុម្មុយនិស្តខ្មែរក្រហម ដែលបំរើរបបកុម្មុយនិស្តជ័តិវ៉ុង បានប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ ដែលជារបបសេរី ។ ដូច្នេះការកាប់សម្លាប់នេះ គឺជាការបោសសំអាតអ្នកមិនមែនកុម្មុយនិស្ត និងអ្នកដែលគេយល់ថា ប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហម ។

ការសម្លាប់នេះ ពុំមែនមនុស្សម្នាក់សម្លាប់មនុស្សម្នាក់ ដោយការចងគំនុំនឹងគ្នាឡើយ គឺជាការសម្លាប់ជាខ្សែសង្វាក់ជាទ្រង់ទ្រាយធំទូទៅទាំងកម្ពុជា ដែលបានរៀបចំយ៉ាងត្រឹមត្រូវរបស់ថ្នាក់ដឹកនាំខ្មែរក្រហម ។ ថ្នាក់ដឹកនាំកំពូលរបស់ខ្មែរក្រហមមិនអាចឆ្លើយថា ខ្លួនពុំដឹងនោះឡើយ ព្រោះខ្មែរក្រហមថ្នាក់ក្រោមមិនហ៊ានធ្វើអ្វីឡើយ បើគ្មានការដាក់ទិសពីខ្មែរក្រហមថ្នាក់លើ ។ មតិរបស់ប្រជាពលរដ្ឋខ្មែរ ចង់ឲ្យកាត់ទោសមនុស្សទាំងអស់ ដែលមានការពាក់ព័ន្ធនឹងការកាប់សម្លាប់នេះ បូករួមទាំងជនបរទេសផង ។ ប៉ុន្តែតុលាការចម្រុះរវាងរាជរដ្ឋាភិបាលខ្មែរនិងអង្គការសហប្រជាជាតិកម្រឹតឧក្រិដ្ឋជន គឺកាត់ទោសខ្មែរក្រហមចំពោះតែខ្មែរក្រហមទទួលខុសត្រូវជាន់ខ្ពស់ប៉ុណ្ណោះ ។

មតិខ្មែរខ្លះទៀតនិយាយរាលដាលដល់ព្រះករុណានរោត្តម-សីហនុ ថាសូមយកព្រះអង្គទៅកាត់ទោស ពុំមែនត្រឹមតែឆ្លើយបំភ្លឺក្នុងតុលាការក្នុងឋានៈជា«សាក្សី»ប៉ុណ្ណោះឡើយ ដោយគេយល់ថា ពួកខ្មែរក្រហមទាំងនោះ ជាសហការីរបស់ព្រះករុណា ក្នុង

រណសិរ្សរួបរួមកម្ពុជា រាជរដ្ឋាភិបាលរួបរួមកម្ពុជា ។ ព្រះករុណាបានអំពាវនាវឲ្យប្រជា-ពលរដ្ឋខ្មែរចូលព្រៃម៉ាគីរួមជាមួយខ្មែរក្រហម ដើម្បីប្រឆាំងនឹងរបបលន់-នល់ និងសហរដ្ឋអាមេរិក ។ គេបន្តថា ព្រះករុណាសីហនុបានដឹកនាំរណសិរ្សនេះផង រាជរដ្ឋាភិបាលនេះផង ហើយបានដើរតួព្រះអង្គឯងផង ។ យុវជននិងយុវនារីខ្មែរបានស្លាប់ជិត១លាននាក់ក្នុងសង្គ្រាម៥ឆ្នាំ ដោយសារការប្រយុទ្ធតទល់យួនកុម្មុយនិស្ត ដែលឈ្លានពានកម្ពុជាក្រោមផ្លាកជួយព្រះករុណាសម្ដេចសីហនុ ។ ក្នុងរយៈកាល៥ឆ្នាំនេះ ព្រះករុណាសីហនុមិនដែលប្រកាសថ្កោលទោសខ្មែរក្រហម ឬប្រកាសដកខ្លួនចេញពីខ្មែរក្រហមឡើយ បានសេចក្ដីថា ព្រះករុណាយល់ស្របតាមការអនុវត្តន៍ធម៌ក្ដៅរបស់ខ្មែរក្រហមតាំងពីស-ង្គ្រាមមក ។ ផ្ទុយទៅវិញ ព្រះអង្គបានយាងទៅអរគុណបរទេស ដែលជួយឧបត្ថម្ភឲ្យខ្មែរក្រហមឈ្នះ ។ មួយទៀតនៅឆ្នាំ១៩៧៩ ព្រះអង្គបានយាងទៅអង្គការសហប្រជាជាតិ តំណាងខ្មែរក្រហម ថ្កោលទោសវៀតណាមដែលឈ្លានពានប្រទេសកម្ពុជាដេញខ្មែរក្រហម ។ ព្រះអង្គបានធ្វើព្រះប្រមុខរដ្ឋខ្មែរក្រហមមួយឆ្នាំទៀត បន្ទាប់ពីខ្មែរក្រហមឈ្នះនៅថ្ងៃ១៧មេសា១៩៧៥ គឺព្រះអង្គបានលាលែងពីព្រះប្រមុខរដ្ឋនៅថ្ងៃទី២មេសា១៩៧៦ ។ ក្នុងរយៈកាលមួយឆ្នាំនេះ ពួកខ្មែរក្រហម ក្រៅពីដេញប្រជាពលរដ្ឋចេញពីក្រុង ខ្មែរក្រហមបានកាប់សម្លាប់អ្នករដ្ឋការលន់-នល់ និងនិស្សិត បញ្ញវ័ន្ត យ៉ាងសាហាវបំផុត ក៏គេពុំឮព្រះអង្គថ្កោលទោសអំពើឧក្រិដ្ឋរបស់ខ្មែរក្រហមឡើយ ។ គេពោលថា ការគំនុំសងសឹករបស់ព្រះអង្គជាមួយរបបលន់-នល់ បានត្រូវខ្មែរស្លាប់រាប់លាននាក់ ក៏ព្រះអង្គមិនសោកស្ដាយអ្វីឡើយ ។

ទ្រង់ស៊ីសុវត្ថិ-ធម្មិកោបានស្នើទៅប្រមុខរាជរដ្ឋាភិបាល ឲ្យលុបចោលតុលាការកាត់ទោសខ្មែរក្រហម ។ សំណើនេះទុកជាការប្រមាថមើលងាយខ្មែរស្លូតត្រង់ ដែលត្រូវខ្មែរក្រហមសម្លាប់ ដោយរារាំងមិនឲ្យយកឧក្រិដ្ឋជនមកកាត់ទោស ។ តុលាការនេះមិនទាន់ធ្វើសវនាការកាត់ទោសខ្មែរក្រហមណាម្នាក់ផង ហេតុដូចម្ដេចបានជាថា ជាតុលាការមិនយុត្តិធម៌ ហើយគេធ្វើនយោបាយ ។

ទ្រង់ធម្មិកោមានបំណងការពារព្រះអតីតព្រះមហាក្សត្រមួយព្រះអង្គ ហើយឲ្យគេលះបង់មិនឲ្យរកយុត្តិធម៌ជូនខ្មែររាប់លាននាក់ដែលត្រូវគេសម្លាប់ ។ សំណើនេះមិនត្រឹមត្រូវទេ ជាការភ័យខ្លួនឯង ព្រោះតុលាការនេះពុំបានចោទព្រះអតីតព្រះមហាក្សត្រទេរហូតមកដល់ពេលនេះ ។ តាមពិតវិញ ព្រះអតីតព្រះមហាក្សត្រខ្មែរគួរប្រើមធ្យោបាយណាមួយ បំភ្លឺប្រជាពលរដ្ឋខ្មែរឲ្យយល់អំពីភាពបរិសុទ្ធរបស់ព្រះអង្គ ថាព្រះអង្គមិនរួមដៃជាមួយខ្មែរក្រហមក្នុងការកាប់សម្លាប់នេះទេ ដើម្បីឆ្លើយតបនឹងពាក្យមន្ទិលសង្ស័យដូចពោលខាងលើ ។ ចំពោះគណបក្សប្រជាជនវិញ គេមិនយកចិត្តទុកដាក់នឹងសំណើនេះឡើយ ហើយបក្សនេះគេបាញ់ព្រួញមួយបានសត្វពីរ ដោយព្រួញមួយ គេចង់ឲ្យមានការិះ

គន់ព្រះមហាក្សត្រ ហើយព្រួញមួយទៀត គេប្រកាសការពារព្រះមហាក្សត្រ ។ ម្តងរិះគន់ព្រះមហាក្សត្រ ដូចជាការចាក់ចម្រៀងស៊ិន-ស៊ីសាមុត ច្រៀងស្តេចលក់ដីឲ្យយៀកកុង ម្តងការពារព្រះមហាក្សត្រ នេះជាផ្លូវនយោបាយ ដើម្បីពង្រឹងគណបក្សប្រជាជនឲ្យរឹងមាំ ឲ្យប្រជាពលរដ្ឋខ្មែរមើលឃើញថា បក្សនេះការពារព្រះមហាក្សត្រសំរាប់សន្លឹកឆ្នោតឆ្នាំ២០០៨ ។

សរុបសេចក្តីមក ត្រូវនាំគ្នាជំរុញតុលាការចំរុះកាត់ទោសខ្មែរក្រហមឲ្យបានឆាប់ មិនត្រូវបង្អាក់ដំណើរឡើយ ទោះបីបានទទួលយុត្តិធម៌ពេញលេញក្តី មិនពេញលេញក្តី ជាជាងមិនបានកាត់ដែរ ព្រោះអស់ពេលជាង១០ឆ្នាំហើយ ទំរាំបង្កើតបានជាតុលាការបែបនេះ ។ បើតុលាការនេះចេញពុំរួចទេ គឺត្រូវចប់ត្រឹមនេះហើយ ពុំអាចបង្កើតតុលាការបែបណាមួយទៀតបានឡើយ ៕

❊ ❊

❊